# ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
# ការពិនិត្យធម្មនុញ្ញភាព

នៅក្នុងប្រវត្តិសាស្ត្រកម្ពុជាពុំដែលមានប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពទេ ។ រដ្ឋធម្មនុញ្ញថ្ងៃទី ០៦ ខែឧសភា ឆ្នាំ១៩៤៧ បានកែប្រែជាបន្តបន្ទាប់រហូតដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ១៩៦៤ ក៏បាននិយាយនៅក្នុងមាត្រា១១៩ តែពីសិទ្ធិបកស្រាយអត្ថបទរដ្ឋធម្មនុញ្ញ ហើយមិនមាននិយាយពីការត្រួតពិនិត្យធម្មនុញ្ញភាពទេ ។ សិទ្ធិបកស្រាយចុងក្រោយជារបស់រដ្ឋសភា ។

រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៧២ បានបង្កើតឲ្យមានប្រព័ន្ធត្រួត-ពិនិត្យធម្មនុញ្ញភាពមួយដែរ ដែលដាក់ឈ្មោះថា **តុលាការធម្មនុញ្ញ** ។ ទោះបីជាមានឈ្មោះតុលាការធម្មនុញ្ញក៏ដោយ ក៏អង្គការនេះស្ថិតនៅដោយឡែកពីអង្គការតុលាការដែរ ។ ការបង្កើតនេះគឺពិតជាទទួលឥទ្ធិពលបស្ចឹមប្រទេសយ៉ាងប្រត្យក្ស ។

ការមកដល់នៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៥ បាននាំមកនូវការកាប់សម្លាប់ប្រជាជន និងកំទេចបំផ្លាញរចនាសម្ព័ន្ធទាំងអស់ ព្រមទាំងជាន់ឈ្លីក្បួនច្បាប់ទាំងឡាយគ្មានសល់រហូតដល់បំណាច់ឆ្នាំ១៩៧៨ ។

ក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ ទន្ទឹមនឹងការកសាងប្រទេសជាតិឡើងវិញគ្រប់វិស័យ ការស្តារប្រព័ន្ធច្បាប់ក៏មានសកម្មភាពខ្លាំងក្លាណាស់ដែរ ។ រដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជាឆ្នាំ១៩៨១ អនុញ្ញាតឲ្យមានការបកស្រាយច្បាប់ដោយក្រុមប្រឹក្សារដ្ឋ ក្នុងឋានៈជាអង្គការអចិន្ត្រៃយ៍របស់រដ្ឋសភា ។ ប៉ុន្តែនៅពេលនោះ ការបកស្រាយរដ្ឋធម្មនុញ្ញ និងការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ពុំទាន់មាននៅឡើយ ។

រដ្ឋធម្មនុញ្ញថ្មីដែលបានអនុម័តនៅថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយសភាធម្មនុញ្ញ ដែលកើតចេញពីការបោះឆ្នោតរៀបចំដោយអង្គការសហប្រជាជាតិឆ្នាំ១៩៩៣ ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ។ ជំពូកទី XII ថ្មីនៃរដ្ឋធម្មនុញ្ញនិយាយអំពីក្រុមប្រឹក្សាធម្មនុញ្ញពីមាត្រា១៣៦ថ្មីរហូតដល់មាត្រា១៤៤ថ្មី ។ នៅក្នុងសមត្ថកិច្ចត្រួតពិនិត្យធម្មនុញ្ញភាព ក្រុមប្រឹក្សធម្មនុញ្ញអាចពិនិត្យជាអាទិកាល ឬជាបច្ឆាកាលនូវធម្មនុញ្ញភាពនៃច្បាប់ លើកលែងតែច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងវិសោធនកម្ម ច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងទាំងនោះដែលត្រូវពិនិត្យធម្មនុញ្ញភាពមុននឹងប្រកាសឲ្យប្រើ ។ មាត្រា ១៣៦ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញចែងថា **ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ** ។ មាត្រា ៩២ នៃរដ្ឋធម្មនុញ្ញ បានចែងថា **ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឲ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិនឹងត្រូវចាត់ទុកជាអសារសូន្យ ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ** ។ មាត្រា ១៦ថ្មី

នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញចែងថា **ច្បាប់រៀបចំអង្គការ និងវិសោធនកម្មនៃច្បាប់រៀបចំអង្គការ ក្រោយពីរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើច្បាប់នោះស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងប្រកាសឲ្យប្រើ ។**

**បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ក្រោយពីព្រឹទ្ធសភាអនុម័តរួច ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យតើបទបញ្ជាផ្ទៃក្នុងនោះស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសឲ្យប្រើ ។**

**បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ក្រោយពីរដ្ឋសភាអនុម័តរួចត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើបទបញ្ជាផ្ទៃក្នុងនោះស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសឲ្យប្រើ ។**

## ១-ការសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់

### ១-១ ការពិនិត្យជាអានិការល

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចត្រួតពិនិត្យសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញដែលព្រះមហាក្សត្រត្រូវតែពិគ្រោះយោបល់ក្រុមប្រឹក្សាធម្មនុញ្ញជាមុន ។ មាត្រា ១៤៣ថ្មីនៃរដ្ឋធម្មនុញ្ញចែងថា **ព្រះមហាក្សត្រ ទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ។**

ក្រោយពីរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ ច្បាប់រៀបចំអង្គការ ឬវិសោធនកម្មនៃច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុង ឬវិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុង ឬវិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ត្រូវដាក់ឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឲ្យប្រើ ។

មាត្រា ១៤០ថ្មី វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញចែងថា **បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឲ្យប្រើ ។**

មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ ចែងថា **ច្បាប់រៀបចំអង្គការ និង វិសោធនកម្មនៃច្បាប់រៀបចំអង្គការ ក្រោយពីរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើច្បាប់នោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងប្រកាសឲ្យប្រើ ។**

**បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង វិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ក្រោយពីព្រឹទ្ធសភាអនុម័តរួច ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យតើបទបញ្ជាផ្ទៃនោះក្នុងស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងប្រកាសឲ្យប្រើ ។**

**បទបញ្ញាផ្ទៃក្នុងរដ្ឋសភា និង វិសោធនកម្មបទបញ្ញាផ្ទៃក្នុងរដ្ឋសភា ក្រោយពីរដ្ឋសភាអនុម័តរួច ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើបទបញ្ញាផ្ទៃក្នុងនោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងប្រកាសឲ្យប្រើ ។**

មាត្រា ១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ ចែងថា **ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ឬសមាជិករដ្ឋសភាចំនួនមួយភាគដប់ អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឲ្យប្រើ ។**

## ១-២ ការពិនិត្យជាបច្ឆាកាល

មាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញបានចែងថា **ក្រោយពីច្បាប់ណាមួយ ត្រូវបានប្រកាសឲ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាមួយភាគបួន តំណាងរាស្ត្រមួយភាគដប់ ឬតុលាការ អាចសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ។**

**ប្រជារាស្ត្រមានសិទ្ធិប្តឹងពីធម្មនុញ្ញភាពនៃច្បាប់បានតាមរយៈតំណាងរាស្ត្រ ឬប្រធានរដ្ឋសភា ឬ សមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។**

មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ ចែងថា **ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឲ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន សមាជិករដ្ឋសភាចំនួនមួយភាគដប់ ឬ តុលាការ អាចសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។**

យោងតាមមាត្រាខាងលើនេះ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ច ត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ បន្ទាប់ពីច្បាប់នោះត្រូវបានប្រកាសឲ្យប្រើ ។ បុគ្គលដែលមានសមត្ថកិច្ច អាចសុំទៅក្រុមប្រឹក្សា-ធម្មនុញ្ញ ដើម្បីត្រួតពិនិត្យធម្មនុញ្ញភាពមុនច្បាប់ប្រកាសឲ្យប្រើ ក៏អាចជាបុគ្គលស្នើសុំឲ្យក្រុមប្រឹក្សា-ធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពក្រោយច្បាប់ត្រូវបានប្រកាសឲ្យប្រើហើយ (មាត្រា ១៤១ថ្មីវាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ) ។

រួមបញ្ចូលទាំងតុលាការដែលអាច ៖ ភាគីដែលជាគូក្តី ឬក៏ចៅក្រមខ្លួនឯង អាចលើកឡើងនូវអញ្ញត្រកម្មអធម្មនុញ្ញភាពនៃច្បាប់ ។ នៅក្នុងរដ្ឋធម្មនុញ្ញមិនបានកំណត់នូវល័ក្ខខ័ណ្ឌការត្រួតពិនិត្យធម្មនុញ្ញភាពដោយអញ្ញត្រកម្មនេះទេ ។ ក៏ប៉ុន្តែមានចែងនៅក្នុងមាត្រា ១៩ វាក្យខណ្ឌទី ១ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា **បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងរឿងក្តីណាមួយ ហើយរឿងក្តីនោះឡើងដល់តុលាការ បុគ្គលនោះអាចលើកអំពីអធម្មនុញ្ញភាពនូវបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬសេចក្តីសម្រេចរបស់ស្ថាប័ននានា ដែលគេអះអាងថា ប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេជូនតុលាការបាន ។** បើយោងតាមមាត្រានេះ សិទ្ធិប្តឹងទៅតុលាការអាចជាសិទ្ធិរបស់ដើមចោទ ចុងចោទ ក៏ដូចជារបស់គូភាគីនៅតុលាការដែរ ។

ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏មាត្រា១៩ វាក្យខ័ណ្ឌទី ២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បន្ថែមថា **បើយល់ឃើញថា ការលើកឡើងនេះ មានមូលដ្ឋានគ្រប់គ្រាន់ តុលាការត្រូវលើកករណីនេះទៅតុលាការកំពូលក្នុងរយៈពេល ១០ថ្ងៃយ៉ាងយូរ។** ចំណុចនេះចៅក្រមវាយតម្លៃពីភាពមានមូលដ្ឋានច្បាស់លាស់របស់បណ្តឹង ប្រសិនបើចៅក្រមយល់ថាមានមូលដ្ឋានច្បាស់លាស់ ចៅក្រមត្រូវបញ្ជូនសំណុំរឿងទៅតុលាការកំពូលដែលត្រូវចាត់ការពិនិត្យ និងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ថ្ងៃយ៉ាងយូរ ដូចក្នុងមាត្រា១៩ វាក្យខ័ណ្ឌទី ៣ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា **តុលាការកំពូលត្រូវចាត់ការពិនិត្យនិងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ថ្ងៃយ៉ាយូរ លើកលែងតែតុលាការកំពូលយល់ឃើញថាពាក្យបណ្តឹងតវ៉ានេះមិនអាចទទួលបាន ។**

តុលាការកំពូលនៅពេលនេះធ្វើការចំរោះ ដោយពិនិត្យជាលើកទីពីរ មុនបញ្ជូនបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

បញ្ញត្តិនេះ មានលក្ខណៈគួរឲ្យកត់សំគាល់យ៉ាងខ្លាំង ដោយសារតែវាមានវិសាលភាពទៅដល់ការត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាល ដែលធ្វើឲ្យក្រុមប្រឹក្សាធម្មនុញ្ញ អាចពិនិត្យបានដោយមានបណ្តឹងពីគូភាគីក្នុងរឿងក្តី ។

លទ្ធភាពឲ្យមានការត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាល ជាការធានាជាអតិបរមានូវការគោរពនីតិរដ្ឋ តាមរយៈការត្រួតពិនិត្យធម្មនុញ្ញភាពដែលមានលក្ខណៈពេញលេញបំផុត ។

## ២- អំពីការប្តឹង

### ២-១ គោលការណ៍ទូទៅ

ជាគោលការណ៍ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចយករឿងណាមួយមកពិនិត្យខ្លួនឯង ដោយគ្មានអ្នកមានសមត្ថកិច្ចស្នើសុំ ឬប្តឹងបានទេ ។ រហូតមកដល់ពេលនេះ ក្រុមប្រឹក្សាធម្មនុញ្ញនៅតែប្រកាន់តាមគោលការណ៍នេះ ។

### ២-២ អ្នកណាខ្លះអាចស្នើសុំ/ប្តឹងបាន

យោងតាមមាត្រា ១៤០ថ្មី វាក្យខ័ណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញចែងថា **ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័តទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងច្បាប់នោះប្រកាសឲ្យប្រើ ។**

មាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញចែងថា **ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឲ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ ឬតុលាការ អាចសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់នោះ ។**

ប្រជារាស្ត្រយមានសិទ្ធិប្តឹងអំពីអធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រ ឬប្រធានរដ្ឋសភា ឬមាជិកព្រឹទ្ធសភា ឬប្រធានរដ្ឋសភា ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

មាត្រា ១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញចែងថា **ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ឬសមាជិករដ្ឋសភាចំនួនមួយភាគដប់ អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឲ្យប្រើ ។**

មាត្រា ១៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញចែងថា **ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឲ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយបួន សមាជិករដ្ឋសភាចំនួនមួយភាគដប់ ឬ តុលាការ អាចសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។**

**ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីអធម្មនុញ្ញភាពនៃច្បាប់ ឬ សុំឲ្យបកស្រាយច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញបានតាមរយៈប្រធានរដ្ឋសភា ឬតំណាងរាស្ត្រ ឬប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភា ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។**

សិទ្ធិដែលផ្តល់ឲ្យអ្នកតំណាងរាស្ត្រចំនួនមួយភាគដប់ និងសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ដើម្បីស្នើសុំមកក្រុមប្រឹក្សាធម្មនុញ្ញមានសារៈសំខាន់ខ្លាំងណាស់ ។ សិទ្ធិនេះផ្តល់ឲ្យមតិភាគតិចក្នុងរដ្ឋសភាក្នុងការសុំឲ្យមានការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ដែលអនុម័តដោយមតិភាគច្រើន ។ វាជាធាតុផ្សំមួយចាំបាច់សំរាប់នីតិរដ្ឋ ។

## ៣- ដំណើរការនៃសំណុំរឿងនៅនាយកដ្ឋានជំនាញ

នៅពេលទទួលបានសំណើរសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ នាយកដ្ឋានជំនាញចុះបញ្ជីក្នុងសៀវភៅទទួលសុំណុំរឿង ។ ក្រោយពីចុះបញ្ជីរួច នាយកដ្ឋានត្រូវរៀបចំកំណត់បង្ហាញរឿងដាក់ឆ្លងតាមឋានានុក្រមរហូតដល់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យ និងសម្រេច ។ ការងារបន្ទាប់របស់នាយកដ្ឋានជំនាញគឺជួយ ដល់ក្រុមប្រឹក្សាធម្មនុញ្ញដូចជា រៀបចំសំណុំរឿងសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាធម្មនុញ្ញ រៀបចំកម្មវិធីលម្អិតជូនថ្នាក់ដឹកនាំសម្រាប់កិច្ចប្រជុំ ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធដើម្បីស្រាវជ្រាវរកឯកសារ តាមតម្រូវការសមាជិករាយការណ៍របស់ក្រុមប្រឹក្សាធម្មនុញ្ញ ចូលរួមជាជំនួយការលេខាធិការកត់ត្រា និងធ្វើកំណត់ហេតុកិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

## ៤- នីតិវិធីដែលត្រូវអនុវត្ត

ដើម្បីអនុវត្តការងារឲ្យមានប្រសិទ្ធភាព និងរលូន ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានបែងចែកជា ៣ក្រុម ដូចមានចែងក្នុងមាត្រា ៣០ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ចែងថា **ដើម្បីស្រាវជ្រាវស៊ើបអង្កេតអំពីវិវាទកម្មទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងជ្រើសតាំងសមាជិកព្រឹទ្ធសភា ក៏ដូចជាការស្រាវជ្រាវត្រួតពិនិត្យធម្មនុញ្ញភាព ឬបកស្រាយច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញចែកចេញជា ៣ក្រុម ។ ក្រុមនីមួយៗមានសមាជិក ៣រូប ដែល ១រូបជាសមាជិកតែងតាំងដោយព្រះមហាក្សត្រ ១រូបជាសមាជិកជ្រើសតាំងដោយរដ្ឋសភា និង ១រូបទៀត**

**តែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ សមាជិកក្នុងក្រុមទាំងបីនេះត្រូវជ្រើសរើសដោយវិធីចាប់ឆ្នោត ក្រោមអធិបតីភាពនៃប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។**

ប្រការ៤ នៃបទបញ្ជាផ្ទៃក្នុងស្ដីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ក៏បានចែងថា **ក្រុមនីមួយៗនៃក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក ៣រូប ដែលមួយរូបជាសមាជិកតែងតាំងដោយព្រះមហាក្សត្រ មួយរូបជាសមាជិកតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងមួយរូបទៀតជាសមាជិកជ្រើសតាំងដោយរដ្ឋសភា ។**

**សមាជិកទាំងបីក្រុមនេះ ត្រូវជ្រើសរើសដោយវិធីចាប់ឆ្នោត ក្រោមអធិបតីភាពនៃប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។**

### ៤-១ ការចាត់តាំងសមាជិករាយការណ៍

នៅពេលច្បាប់ដែលត្រូវបានស្នើសុំមកក្រុមប្រឹក្សាធម្មនុញ្ញ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញចាត់តាំងសមាជិកម្នាក់ឲ្យធ្វើជាសមាជិករាយការណ៍ ។ របាយការណ៍របស់សមាជិករាយការណ៍ជាមូលដ្ឋានសំខាន់មួយសម្រាប់ពិចារណា ។ យោងតាមមាត្រា ២២ថ្មីវាក្យខ័ណ្ឌទី២ នៃច្បាប់ស្ដីពី វិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ចែងថា **ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពិចារណាលើធម្មនុញ្ញភាព ឬបកស្រាយច្បាប់ ដោយផ្អែកលើសេចក្ដីរាយការណ៍របស់សមាជិកដែលប្រធានបានប្រគល់ភារកិច្ចឲ្យពិនិត្យរាយការណ៍ ។ សមាជិករាយការណ៍ជាសមាជិកនៃក្រុមរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា៣០ នៃច្បាប់នេះ ។**

ប្រការ៣ថ្មី នៃបទបញ្ជាផ្ទៃក្នុងស្ដីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ក៏បានចែងថា **ក្រោយពីចុះបញ្ជីរួច ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជូនសំណើទាំងនោះទៅសមាជិករាយការណ៍ក្នុងក្រុមណាមួយនៃក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យ ។ របាយការណ៍របស់ក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវដាក់ជូនអង្គប្រជុំបឋមដើម្បីពិភាក្សា ។**

### ៤- ២ ភារកិច្ចរបស់សមាជិករាយការណ៍

បន្ទាប់ពីប្រធានក្រុមប្រឹក្សាធម្មនុញ្ញចាត់តាំងសមាជិករាយការណ៍ សមាជិករាយការណ៍ត្រូវកោះប្រជុំក្រុមដោយមានមន្ត្រីសេវាកម្មច្បាប់ចូលរួមជាលេខាធិការកត់ត្រា ។ សមាជិករាយការណ៍អាចស្នើសុំប្រធានក្រុមប្រឹក្សាធម្មនុញ្ញឲ្យអញ្ជើញបុគ្គលឯកជន ឬបុគ្គលសាធារណៈម្នាក់ ឬច្រើននាក់ដើម្បីសុំឲ្យអ្នកទាំងនោះផ្ដល់ការបំភ្លឺ ឬផ្ដល់ឯកសារផ្សេងៗទាក់ទងនឹងសំណុំរឿងដែលកំពុងពិនិត្យ ។ ការអញ្ជើញចាំបាច់ត្រូវតែមានចំពោះសំរាប់បុគ្គលផ្សេងៗដែលពាក់ព័ន្ធ ដូចក្នុងមាត្រា ២១នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ចែងថា **ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិអញ្ជើញជនណាម្នាក់ ឬច្រើននាក់មកបំភ្លឺ ឬផ្ដល់ឯកសារដែលពាក់ព័ន្ធបាន ។ បុគ្គលគ្រប់រូបស្ថាប័នរដ្ឋ ឬឯកជនទាំងឡាយ ត្រូវគោរព និងប្រតិបត្តិតាមការអញ្ជើញ និងការស្នើសុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។**

ក្រោយពីសិក្សាលើច្បាប់ហើយ ក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវធ្វើរបាយការណ៍ស្ដីពីការពិនិត្យធម្មនុញ្ញភាពដើម្បីដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញនាសម័យប្រជុំបឋមដើម្បីពិនិត្យ និងពិភាក្សា ។

**៥- សេចក្តីសម្រេច**

បន្ទាប់ពីក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើរបាយការណ៍ស្តីពីការពិនិត្យធម្មនុញ្ញភាពចប់រួចរាល់ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវធ្វើលិខិតអញ្ជើញសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីចូលរួមប្រជុំពិភាក្សាទៅលើរបាយការណ៍របស់ក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ យោងតាមមាត្រា១៨ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ចែងថា **កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ឬដោយសមាជិកដែលមានអាយុច្រើនជាងគេដែលមានវត្តមាន បើប្រធានមានធុរៈមិនអាចធ្វើបាន ។**

ប្រការ១២ថ្មីវាក្យខ័ណ្ឌទី១ នៃបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញក៏បានចែងថា **កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ឬដោយសមាជិកដែលមានអាយុច្រើនជាងគេដែលមានវត្តមាន បើប្រធានមានធុរៈមិនអាចធ្វើបាន ។**

លិខិតអញ្ជើញប្រជុំត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាធម្មនុញ្ញយ៉ាងតិច២ថ្ងៃ មុនថ្ងៃកំណត់ប្រជុំ លើកលែងតែការប្រញាប់ ។ យោងតាមប្រការ១៣ថ្មីវាក្យខ័ណ្ឌទី១ នៃបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញបានចែងថា **ការកោះប្រជុំត្រូវធ្វើជាលិខិតអញ្ជើញភ្ជាប់ជាមួយគម្រោងរបៀបវារៈ ហើយផ្ញើជូនសមាជិកយ៉ាងតិច ២ថ្ងៃ មុនថ្ងៃកំណត់ប្រជុំ លើកលែងតែការប្រញាប់ ។**

**៥-១ កិច្ចប្រជុំបឋម**

ដើម្បីអាចប្រជុំបាន ក្រុមប្រឹក្សាធម្មនុញ្ញត្រូវមានកូរ៉ុមលើសពីពាក់កណ្តាល ដូចមានក្នុងមាត្រា១៨ថ្មី វាក្យខ័ណ្ឌទី២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា **កិច្ចប្រជុំក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់ទុកជាបានការ លុះត្រាតែមានសមាជិកលើសពីពាក់កណ្តាលចូលរួមប្រជុំ ។** នៅក្នុងប្រការ១២ថ្មី វាក្យខ័ណ្ឌទី២ នៃបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញក៏បានចែងថា **កិច្ចប្រជុំក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់ទុកជាបានការ លុះត្រាតែមានសមាជិកលើសពីពាក់កណ្តាលចូលរួមប្រជុំ ។** នៅក្នុងកិច្ចប្រជុំបឋមនេះ សមាជិករាយការណ៍ត្រូវតែរាយការណ៍ជូនក្រុមប្រឹក្សាធម្មនុញ្ញដូចដែលមានក្នុងរបាយការណ៍ដើម្បីពិភាក្សា ។ សមាជិកទាំងអស់បញ្ចេញមតិយោបល់ ថាតើរបាយការណ៍នេះបានពិនិត្យគ្រប់ជ្រុងជ្រោយ ឬនៅខ្វះខាតមុននឹងដាក់ចូលក្នុងកិច្ចប្រជុំពេញអង្គពិនិត្យ និងសម្រេច ។

**៥-២ កិច្ចប្រជុំពេញអង្គ**

យោងតាមមាត្រា ២២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា **ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្តីជាលាយលក្ខអក្សរលើគ្រប់ករណីដែលត្រូវបានដាក់ជូនក្នុងរយៈពេល ៣០ថ្ងៃ ។ ប្រសិនបើជាការប្រញាប់ រយៈពេលនេះត្រូវបន្ថយមកត្រឹម ៨ថ្ងៃ ។**

**ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពិចារណាលើធម្មនុញ្ញភាព ដោយផ្អែកលើសេចក្តីរាយការណ៍របស់សមាជិកដែលប្រធានបានប្រគល់ភារកិច្ចឲ្យពិនិត្យរាយការណ៍ ។**

កិច្ចប្រជុំពេញអង្គ ពិនិត្យ និងសម្រេចលើច្បាប់នោះថាតើស្របនឹងរដ្ឋធម្មនុញ្ញ ឬមិនស្រប រដ្ឋធម្មនុញ្ញ ឬមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញ ។ ត្រង់ចំណុចនេះ មាត្រា ២០ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា **បើក្រុមប្រឹក្សាធម្មនុញ្ញកំណត់ថាបទប្បញ្ញត្តិមួយនៃច្បាប់មិនស្របនឹងរដ្ឋធម្មនុញ្ញ៖**

**ក-បើបទប្បញ្ញត្តិនោះមិនអាចបំបែកចេញពីអត្ថបទដែលនៅសល់បានទេ អត្ថបទច្បាប់ទាំងមូលមិនអាចយកទៅប្រកាសឲ្យប្រើ ឬយកទៅអនុវត្តបានឡើយ ។**

**ខ-បើបទប្បញ្ញត្តិនោះអាចបំបែកចេញពីអត្ថបទដែលនៅសល់បាននោះ មានតែបទប្បញ្ញត្តិដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ ដែលមិនអាចយកទៅប្រកាសឲ្យប្រើ ឬយកទៅអនុវត្តបាន ។**

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្ដីតាមមតិភាគច្រើនលើសម្លេងដាច់ខាតនៃសមាជិកទាំងមូល ដូចមានចែងក្នុងមាត្រា ២២ថ្មី វាក្យខ័ណ្ឌទី៣ នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ប្រការ ៧ នៃបទបញ្ជាផ្ទៃក្នុងស្ដីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា **ចំពោះគ្រប់សំណើឲ្យពិនិត្យខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចក្នុងពេលវេលាមួយដែលមានកំណត់ក្នុងច្បាប់ និងតាមមតិភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ទាំងមូល (៥សំលេងយ៉ាងតិច) ។**

ទោះបីចំនួនសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនគត់ក៏ដោយ (៩រូប) ប៉ុន្តែសម្លេងអាចស្មើគ្នាបាន ដោយសារតែវត្តមានរបស់សមាជិក មិនមែនចាំបាច់ខានមិនបាននោះទេ មានន័យថា អាចមានសមាជិកអវត្តមាន ។ យោងតាមមាត្រា ១៩ថ្មី វាក្យខ័ណ្ឌទី ២ នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា **កិច្ចប្រជុំក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់ទុកជាបានការលុះត្រាតែមានសមាជិកលើសពីពាក់កណ្ដាលចូលរួមប្រជុំ ។** ចំណែកឯបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ ប្រការ១២ថ្មី ក៏បានចែងពីកូរ៉ុមនេះដែរ ។ ដូច្នេះប្រសិនបើមានវត្តមានតែ ៨រូប អាចមានសំលេងស្មើគ្នា ។ ក្នុងករណីនេះ មាត្រា ២២ថ្មីនៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ចែងថា សម្លេងប្រធានមានឧត្តមានុភាព ។ ចំណែកឯប្រការ ១៩ នៃបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញក៏បានចែងថា **ក្នុងការអនុម័តតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល បើចំនួនមតិយល់ព្រម និងមតិមិនយល់ព្រមស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សា-ធម្មនុញ្ញត្រូវមានឧត្តមានុភាព ។**

### ៥-៣ អានុភាពនៃសេចក្ដីសម្រេច

សេចក្ដីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសម្រេចស្ថាពរ និងបិទផ្លូវតវ៉ា។ សេចក្ដីសម្រេចទាំងនេះមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ បទប្បញ្ញត្តិទាំងឡាយណាមួយនៃច្បាប់ដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាវាមិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសឲ្យប្រើ ឬអនុវត្តបានទេ ៖

ក-បើបទប្បញ្ញត្តិនោះមិនអាចបំបែកចេញពីអត្ថបទដែលនៅសល់បានទេ អត្ថបទច្បាប់ទាំងមូលមិនអាចយកទៅប្រកាសឲ្យប្រើ ឬយកទៅអនុវត្តបានឡើយ ។

ខ-បើបទប្បញ្ញត្តិនោះអាចបំបែកចេញពីអត្ថបទដែលនៅសល់បាននោះ មានតែបទប្បញ្ញត្តិដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ ដែលមិនអាចយកទៅប្រកាសឲ្យប្រើ ឬយកទៅអនុវត្តបាន ។ ដូចក្នុងមាត្រា ១៤២ថ្មី នៃរដ្ឋធម្មនុញ្ញបានចែងថា **បទប្បញ្ញត្តិក្នុងមាត្រាណាដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញមិនអាចយកទៅប្រកាសឲ្យប្រើ ឬយកទៅអនុវត្តបានឡើយ ។** មាត្រា ២៣ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា **សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែបង្ហាញហេតុផល (មាត្រា ២២ថ្មី វាក្យខ័ណ្ឌទី៤ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ) ។

ដើម្បីឲ្យសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញមានការជ្រួតជ្រាប ដោយមានប្រសិទ្ធភាព សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវផ្ញើថ្វាយព្រះមហាក្សត្រ ជូនព្រឹទ្ធសភា រដ្ឋសភា នាយករដ្ឋមន្ត្រី តុលាការកំពូល និងត្រូវបោះពុម្ពផ្សាយនៅក្នុងរាជកិច្ច ។ ដូចក្នុងមាត្រា ២៤ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា **សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវផ្ញើថ្វាយព្រះមហាក្សត្រ ជូនប្រធានព្រឹទ្ធសភា ជូនប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានតុលាការកំពូល និងចុះផ្សាយក្នុងរាជកិច្ច ។**

**ប្រធានព្រឹទ្ធសភាត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិកព្រឹទ្ធសភាទាំងអស់ ។**

**ប្រធានរដ្ឋសភាត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិករដ្ឋសភាទាំងអស់ ។**

**នាយករដ្ឋមន្ត្រីត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិករាជរដ្ឋាភិបាលទាំងអស់ ។**

**ប្រធានតុលាការកំពូលត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់តុលាការសាមី ។**

ចាប់តាំងពីការកកើតក្រុមប្រឹក្សាធម្មនុញ្ញពីថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ១៩៩៨ រហូតមកដល់បច្ចុប្បន្ន ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលពិនិត្យធម្មនុញ្ញភាពនៃច្បាប់មានចំនួន ៦០ ករណី និងថ្វាយមតិព្រះមហាក្សត្រលើសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញចំនួន ០៦ ករណី ។ ក្នុងចំណោម ០៦ ករណីនេះ សូមលើកចុតហ្មាយមួយមកបង្ហាញជាឧទាហរណ៍

-ចុតហ្មាយលេខ ០០១/០១/២០០៦ កបធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី(មួយ) មាត្រា ១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ។ តាមការពិនិត្យលើសេចក្តីព្រាងច្បាប់ធម្មនុញ្ញនេះ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថាពុំមានអ្វីប៉ះពាល់ដល់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញឡើយ ។ ម៉្យាងវិញទៀតក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ការស្នើធ្វើវិសោធនកម្មមាត្រាទាំងអស់ខាងលើនេះ ធ្វើឡើងក្នុងកាលៈទេសៈធម្មតារបស់ប្រទេសជាតិ អាចធ្វើបាន ។

ការពិនិត្យធម្មនុញ្ញភាពទាំង ៦០ ករណីនេះ មានករណីមាន ០៥ ករណីជាការពិនិត្យធម្មនុញ្ញភាពបច្ឆាកាល និង៥៥ ករណីជាការពិនិត្យធម្មនុញ្ញភាពអាទិកាល ។

ក្នុងចំណោមការពិនិត្យជាបច្ឆាកាលទាំង ០៥ ករណីនេះ សូមលើកយកមួយករណីមកបង្ហាញជាឧទាហរណ៍

-សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ កបធ.ច ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីព្រះរាជសាររបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ថា ជាគោលការណ៍ ក្នុងការជំនុំជម្រះក្តី ចៅក្រមពុំមែនគ្រាន់តែផ្អែកទៅលើមាត្រា ៨នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋតែមួយនេះទេដើម្បីផ្តន្ទាទោសលើឧក្រិដ្ឋជន ប៉ុន្តែចៅក្រមត្រូវតែផ្អែកលើច្បាប់ ។ ពាក្យថាច្បាប់ខាងលើមានន័យថា ច្បាប់ជាតិ រួមមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ច្បាប់ទាំងឡាយដែលមាននៅជាធរមាន ហើយនិងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

ក្នុងចំណោមការពិនិត្យជាអាទិកាលទាំង ៥៥ករណី នេះ មានករណីមួយចំនួនត្រូវបានប្រកាសថាអធម្មនុញ្ញភាព ដូចជា៖

-សេចក្តីសម្រេចលេខ ០៩ កបធ.សសរ.ច ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ១៩៩៩ ស្តីពីការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។ ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ដែលត្រូវបានស្នើសុំមកក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាព ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យ និងសម្រេចថា **ខ្លឹមសារមាត្រា ៣ នៃច្បាប់នេះ ដែលចែងថា «ក្រសួងកិច្ចការនារី និងអតីតយុទ្ធជនត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូបជានារី...» បានប៉ះពាល់ទៅលើគោលការណ៍ជាសារវន្តនៃមាត្រា ៣១ កថាខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា «ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នា ទាំងអស់ដោយឥតមានប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ...» និងមាត្រា ៤៥ វាក្យខ័ណ្ឌទី៣នៃរដ្ឋធម្មនុញ្ញ ដែលចែងថា «បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់...»។ ការតម្រូវឲ្យតែស្ត្រីទើបអាចធ្វើរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និង អតីតយុទ្ធជន គឺនាំឲ្យមានការរើសអើងពីរឿង «ភេទ» និងនាំឲ្យបាត់សមភាព ក្នុងសិទ្ធិនយោបាយរវាងបុរស និងស្ត្រី ដែលមាត្រា ៣១ និង ៤៥ នៃរដ្ឋធម្មនុញ្ញបានការពារ ។**

ដូច្នេះ ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ត្រូវបានប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ ។

-សេចក្តីសម្រេចលេខ០៣៥/០០១/២០០០ កបធ.ច ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ២០០០ ស្តីពីការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ។ មាត្រា ៤០ នៃច្បាប់នេះចែងថា **គណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងនាមរដ្ឋសភា មានសិទ្ធិជ្រើសរើសសវនករពិសេស ដើម្បីពិនិត្យមើលឡើងវិញនូវសកម្មភាព និងកិច្ចសហប្រតិបត្តិការរបស់អាជ្ញាធរសវនកម្ម** ។ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យ និងសម្រេចថា ជាគោលការណ៍ គណៈកម្មាធិការអចិន្ត្រៃរបស់រដ្ឋសភា មិនអាចតំណាងឲ្យរដ្ឋសភាទេ ។

ដូច្នេះ ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែមាត្រា ៤០ ។

-សេចក្តីសម្រេចលេខ០៤០/០០២/២០០១ កបធ.ច ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពី ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ មាត្រា ៣ វាក្យខ័ណ្ឌទី១ នៃច្បាប់នេះ បានយោងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ និងចង្អុលមាត្រានៃក្រមព្រហ្មទណ្ឌនេះ ចំនួនដប់ ដែលក្នុងចំណោមនោះមាត្រា ២០៩ ៥០០ និង៥០៧ បានចែងថា **...ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីបី។** មាត្រា ២១ នៃក្រមព្រហ្មទណ្ឌដដែលបានបញ្ជាក់ថា **...ទោសឧក្រិដ្ឋថ្នាក់ទីបី គឺជាទោសសម្លាប់** ។ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យ និងសម្រេចថា ទាំងអក្សរ ទាំងខ្លឹមសារវាក្យខ័ណ្ឌពាក់ព័ន្ធនេះ មានន័យផ្ទុយនឹងរដ្ឋធម្មនុញ្ញ ដែលមានមាត្រា ៣២ វាក្យខ័ណ្ឌទី ២ បានចែងថា **ទោសប្រហារជីវិតមិនត្រូវឲ្យមានឡើយ** ។

ដូច្នេះ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែមាត្រា ៣ នៃច្បាប់នេះ ។

-សេចក្តីសម្រេចលេខ០៤ កបធ.សសរ.ច ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។ ប្រការ ៤៨ ដែលចែងថា ការជ្រើសតាំងប្រធានបណ្តោះអាសន្នមួយរូបឲ្យដឹកនាំការប្រជុំបន្ត ។ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យ និងសម្រេចថា ការជ្រើសតាំងប្រធានបណ្តោះអាសន្នមួយរូបឲ្យដឹកនាំការប្រជុំបន្ត ពុំមានចែងក្នុងរដ្ឋធម្មនុញ្ញទេ និជាប្រការមួយពិបាកនឹងអនុវត្តក្នុងការជាក់ស្តែង ។

ដូច្នេះ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាមាន ១៦ជំពូក និង៨០ ប្រការ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែប្រការ ៤៨ ដែលមិនស្របនឹងមាត្រា ១១០ថ្មី នៃរដ្ឋធម្មនុញ្ញ ។

-សេចក្តីសម្រេចលេខ : ០៧៧/០០៤/២០០៦ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០០៦ ស្តីពីការពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យ និងសម្រេចថា ប្រការ ៖

+ប្រការ ៥ ចំណុច ខ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី ២ ដែលចែងថា "ការិយាល័យបណ្តោះអាសន្នមានភារកិច្ចជ្រើសតាំងប្រធាន និង អនុប្រធានទាំងពីររបស់ព្រឹទ្ធសភា " មិនស្របនឹងមាត្រា ១០៦ថ្មី (មួយ)នៃរដ្ឋធម្មនុញ្ញ

+ប្រការ ១៩ កថាខ័ណ្ឌទី ២ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី ២ ដែលចែងថា "ក្នុងករណីពិសេសបន្ទាន់ដែលមិនអាចបោះឆ្នោតដាច់ដោយឡែកពីគ្នាបាន ការបោះឆ្នោតអាចធ្វើឡើងក្នុងពេលតែមួយ មានទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ បាន។ សន្លឹកឆ្នោតត្រូវធ្វើដាច់ដោយឡែកពីគ្នា " មិនស្របនឹងមាត្រា ១០៦ ថ្មី (មួយ) វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ

+ប្រការ ២០ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី ២ ដែលចែងថា "កាលបើជ្រើសរើសប្រធាន និង អនុប្រធានបាន ហើយប្រធានការិយាល័យបណ្តោះអាសន្នត្រូវប្រកាសបញ្ចប់ភារកិច្ចរបស់

ការិយាល័យបណ្តោះអាសន្ន ហើយប្រគល់ការងារជូនប្រធានព្រឹទ្ធសភាដែលទើបបានជ្រើសតាំង ” មិនស្របនឹងមាត្រា ១០៦ ថ្មី(មួយ) កថាខណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ

+ប្រការ ២៥ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី ២ មិនស្របនឹងមាត្រា ១០៦ថ្មី (មួយ) កថាខណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ

+ប្រការ ១០៩ កថាខណ្ឌទី ២ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី ២ បានចែងថា "ក្នុងករណីទុញទាល់ពុំមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនេះទេ ប្រធានព្រឹទ្ធសភាត្រូវសុំការសម្រេចពីគណៈកម្មាធិការអចិន្ត្រៃយ៍ ឬ ពីសម័យប្រជុំ ពេញអង្គអំពីនីតិវិធីសមស្របដែលត្រូវយកមកអនុវត្ត ” មិនស្របនឹងមាត្រា ១៤០ ថ្មី កថាខណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ

ដូច្នេះ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែប្រការ ៥ ចំណុច ខ ដែលមិនស្របនឹងមាត្រា ១០៦ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ ប្រការ១៩ កថាខណ្ឌទី២ ប្រការ២០ ប្រការ២៥ មិនស្របនឹងមាត្រា១០៦ថ្មី(មួយ) កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ និងប្រការ១០៩ មិនស្របនឹងមាត្រា ១៤០ថ្មី កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ ។

-សេចក្តីសម្រេចលេខ : ០៥៩/០០១/២០០៤ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០០៤ ស្តីពីការពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ។ ប្រការ ៥១ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភានីតិកាលទី ៣ ដែលចែងថា " ក្នុងពេលប្រជុំណាមួយ បើប្រធាន និង អនុប្រធានមិននៅ ដោយមានហេតុការណ៍អ្វីជាពិសេសនោះ រដ្ឋសភាអាចជ្រើសតាំងប្រធានបណ្តោះអាសន្នមួយរូបឱ្យដឹកនាំការប្រជុំ ” មិនស្របនឹងមាត្រា ៨៧ថ្មី នៃរដ្ឋធម្មនុញ្ញ ។ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យ និងសម្រេចថា បទប្បញ្ញត្តិនៃប្រការ៥១ នេះ ជាប្រការមួយមានការលំបាកក្នុងការអនុវត្តជាក់ស្តែង ហើយមិនស្របនឹងមាត្រា ៨៧ថ្មី នៃរដ្ឋធម្មនុញ្ញ ។

ដូច្នេះ បទបញ្ជាផ្ទៃក្នុងរដ្ឋសភាដែលមាន ១៧ជំពូក និង ៨៣ប្រការត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញលើកលែងតែប្រការ ៥១ ដែលមិនស្របនឹងមាត្រា ៨៧ថ្មី នៃរដ្ឋធម្មនុញ្ញ ។

ចាប់តាំពីការករកើតក្រុមប្រឹក្សាធម្មនុញ្ញពីឆ្នាំ ១៩៩៨ រហូតមកដល់បច្ចុប្បន្ន ក្រុមប្រឹក្សាធម្មនុញ្ញបានបំពេញតួនាទីយ៉ាងខ្ជាប់ខ្ជួនស្របតាមរដ្ឋធម្មនុញ្ញ ជាស្ថាប័នកំពូល ឯករាជ្យសម្រាប់ការពាររដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ការបំពេញតួនាទីរបស់ខ្លួន ជាពិសេសការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាពនៃច្បាប់ដែលរដ្ឋសភាបានអនុម័ត ។ ការពិនិត្យ ពិភាក្សា និងសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញធ្វើឡើងឈរលើមូលដ្ឋានឯករាជ្យ និងស្រាវជ្រាវគ្រប់ជ្រុងជ្រោយ និងសម្រេចជាសមូហភាព ។ ដោយការ ប្រកាន់យកជំហរឯករាជ្យ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានមហាជនស្គាល់

និងទទួលសារទេរនូវការងាររបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលពីមុនមហាជនភាគច្រើនលើសលប់មិនស្គាល់អ្វីជាក្រុមប្រឹក្សាធម្មនុញ្ញនោះឡើយ។

**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ**
**នៃព្រះរាជាណាចក្រកម្ពុជា**